# អ្វីៗដែលទាក់ទងទៅនឹងសេចក្ដីសុចរិត

*អែលឌើរ ប្រានស៊ីស្កូ ជេ វីណាស*

*នៃពួកចិតសិបនាក់*

យើងត្រូវបានប្រាប់នៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញាថា បន្ទាប់ពីទីបន្ទាល់របស់ពួក អ្នកបំរើរបស់ព្រះ នោះទីបន្ទាល់ អំពីការរញ្ជួយដី និងទីបន្ទាល់អំពីព្រឹត្តិការណ៍ផ្សេងៗទៀត នឹងកើតមានតាមមក។ «ហើយគ្រប់ទាំងអស់នឹងនៅក្នុង ស្ថានភាពចលាចល ហើយប្រាកដមែន មនុស្សលោកនឹងស្រយុតចិត្ត ព្រោះសេចក្ដីភ័យខ្លាចនឹងមានមកលើអស់ទាំង មនុស្ស» (គ. និង ស. 88:91)។

យើងកំពុងតែមើលឃើញភស្តុតាងនៃសេចក្ដីពិត ដែលវិវរណៈនៅក្នុងការរញ្ជួយដីបច្ចុប្បន្ន នៅកោះ ហៃទី និងប្រទេសឈីលី។ ក្នុងនាមជាសមាជិកមួយរូបនៃគណៈប្រធានតំបន់ការីប៊ីន ខ្ញុំធ្វើជាសាក្សីដោយផ្ទាល់ អំពីការខូចខាត និងភាពអស់សង្ឃឹម ដែលប្រជាជនហៃទីបានរងទុក្ខមិនអាចពិពណ៌នាបាន។

អារម្មណ៍អំពីការបំផ្លិចបំផ្លាញដ៏អាក្រក់នោះ បានកើតមាននៅក្នុងគំនិតរបស់ខ្ញុំ នូវពាក្យសំដីនៅក្នុងជំពូកទីម្ភៃប្រាំបី ក្នុងគម្ពីរអាលម៉ាថា «នេះជាពេលមួយដែលមានការកាន់ទុក្ខដ៏ធំ ហើយសម្លេងទួញសោក បានឮទូទៅអស់ទាំងដែនដី នៅក្នុងចំណោមប្រជាជននីហ្វៃទាំងអស់» (អាលម៉ា 28:4)។ មានមនុស្ស ពីរម៉ឺននាក់ បានបាត់បង់ជីវិតរបស់ពួកគេ «មនុស្សជាច្រើនពាន់នាក់កំពុងតែកាន់ទុក្ខ ចំពោះការបាត់បង់ ញាតិសណ្ដានរបស់គេ ពីព្រោះគេមានហេតុនឹងភ័យ» (អាលម៉ា 28:11)។

មានសមាជិកចំនួនសែសិបពីរនាក់ ក៏បានបាត់បង់ជីវិតរបស់ពួកគេ ដែលធ្វើឱ្យក្រុមគ្រួសារ និងមិត្តភក្តិរបស់ពួកគេ «កាន់ទុក្ខយ៉ាងពិតប្រាកដចំពោះការបាត់បង់ញាតិសណ្ដានរបស់គេ តែគេអររីករាយ ហើយរំភើបនៅក្នុងសេចក្ដីសង្ឃឹម ហើយដោយដឹងថា ស្របទៅតាមពាក្យសន្យាទាំងឡាយនៃព្រះអម្ចាស់ នោះពួកគេនឹងត្រូវបានប្រោសឡើងវិញ ដើម្បីនៅខាងស្ដាំព្រះហស្តនៃព្រះ នៅក្នុងស្ថានភាពនៃសុភមង្គល ដ៏មិនចេះចប់មិនចេះហើយ» (អាលម៉ា 28:12)។

ជំនួយជាបន្ទាន់ត្រូវបានបញ្ជូនទៅដោយសាសនាចក្រ ចំពោះសមាជិក និងអ្នកដែលពុំមែនជាសមាជិក ហើយត្រូវបានចែកចាយនៅក្រោមការដឹកនាំរបស់អ្នកដឹកនាំបព្វជិតភាព និងពួកអ្នកដឹកនាំសមាគមសង្គ្រោះប្រចាំតំបន់។ ពួកគេមិនត្រឹមតែទទួលជំនួយខាងពេទ្យ ទឹក និងសម្ភារចាំបាច់ដទៃទៀតតែប៉ុណ្ណោះទេ ពួកគេក៏បានទទួលការប្រឹក្សា ការដឹកនាំ និងការលួងលោមចិត្តមកពីពួកអ្នកដឹកនាំប្រចាំតំបន់របស់ពួកគេផងដែរ។ ពួកគេមានការគាំទ្រពីសមាជិក នៃសាសនាចក្រនៅក្នុងពិភពលោកដែល «ទួញយំជាមួយនឹងអ្នកណាដែលទួញយំ មែនហើយ ហើយកំសាន្តទុក្ខដល់អស់អ្នកណា ដែលកំពុងត្រូវការកំសាន្តទុក្ខ»

(ម៉ូសាយ 18:9)។

ព្យាការីផ្សេងៗនៅក្នុងជំនាន់ខុសៗគ្នា បានព្រមានដល់យើងអំពីសោកនាដកម្មដទៃទៀត ដែលមិនអាចយល់បាន ប៉ុន្តែមិនមែនមិនសូវសំខាន់នោះទេ ហើយនោះគឺជា «សេចក្ដីស្លាប់ដ៏គួរស្ញែងខ្លាច នឹងមកដល់ពួកទុច្ចរិត ព្រោះពួកគេស្លាប់ចំពោះអ្វីៗដែលទាក់ទងទៅនឹងសេចក្តីសុចរិត ព្រោះពួកគេឥតស្អាត ហើយគ្មានអ្វីដែលឥតស្អាត អាចគ្រងនគរព្រះ ទុកជាមរតកបានឡើយ» (អាលម៉ា 40:26)។

នីហ្វៃបានបង្រៀនគោលការណ៍នេះ ទៅដល់បងប្អូនប្រុសរបស់គាត់ ដោយប្រាប់ពួកគេថា អ្នកទាំងឡាយណាដែល «ស្លាប់នៅក្នុងអំពើទុច្ចរិតរបស់គេ នោះពួកគេនឹងត្រូវបោះបង់ចេញពីអ្វីៗខាងវិញ្ញាណ ដែលទាក់ទងទៅនឹង សេចក្ដីសុចរិតដែរ» (នីហ្វៃទី 1 15:33)។

ព្យាការីសាសន៍លេមិន ឈ្មោះសាំយ៉ូអែល បានបង្រៀនថា «អស់អ្នកណាដែលពុំប្រែចិត្តទេ នោះនឹងត្រូវកាប់រំលំ ហើយបោះចោលទៅក្នុងភ្លើងវិញ ហើយសេចក្ដីស្លាប់ខាងវិញ្ញាណ ក៏កើតមានដល់គេជាថ្មី មែនហើយ គឺជាសេចក្ដីស្លាប់ទីពីរ ព្រោះពួកគេត្រូវបានកាត់ជាថ្មីចេញពីអ្វីៗដែលទាក់ទងទៅនឹងសេចក្ដីសុចរិត» (ហេលេមិន 14:18)។

សោកនាដកម្មនៃការស្លាប់ចំពោះអ្វីៗដែលជារឿងខាងវិញ្ញាណ មានឥទ្ធិពលធំជាង សម្រាប់អ្នកទាំងឡាយដែល «បានបំភ្លឺដោយព្រះវិញ្ញាណនៃព្រះ ហើយដែលធ្លាប់មានការចេះដឹងដ៏ច្រើនអំពីការណ៍ ទាំងឡាយដែលទាក់ទងទៅនឹង សេចក្ដីសុចរិត តែបន្ទាប់មកបានធ្លាក់ក្នុងអំពើបាប និងអំពើរំលង នោះពួកគេ ក្លាយទៅជារឹងរូសលើសលែងទៅទៀត ម្ល៉ោះហើយ ស្ថានភាពរបស់គេក្លាយទៅជាអាក្រក់ ជាជាងបើគេមិនដែលបានស្គាល់ការណ៍ទាំងនេះទៅវិញ» (អាលម៉ា 24:30)។

ក្នុងនាមជាឪពុកម្ដាយ និងពួកអ្នកដឹកនាំ យើងចាំបាច់ត្រូវមើលលើសមាជិក និងក្រុមគ្រួសាររបស់យើង ជួយពួកគេឱ្យនៅឆ្ងាយពីអ្វីដែលអាចដឹកនាំពួកគេទៅរកសេចក្ដីស្លាប់ខាងវិញ្ញាណ។ យើងក៏ព្យាយាមជួយសង្គ្រោះ ដល់អ្នកទាំងឡាយដែលស្លាប់ ចំពោះរឿងទាំងឡាយ ដែលជារឿងខាងវិញ្ញាណ ហើយជួយពួកគេ «កើតម្ដងទៀត មែនហើយកើតមកពីព្រះ ផ្លាស់ប្រែពីស្ថានភាពខាងរូបកាយ និងខាងការធ្លាក់ ទៅកាន់ស្ថានភាពនៃសេចក្ដីសុចរិតវិញ ដោយបានព្រះទ្រង់ប្រោសលោះ នោះនឹងក្លាយទៅជាបុត្រា បុត្រីរបស់ទ្រង់» (ម៉ូសាយ 27:25)។

ការព្យាបាលខាងវិញ្ញាណដល់មនុស្សស្លាប់ចំពោះអ្វីៗដែលទាក់ទងទៅនឹងសេចក្ដីសុចរិត កើតមកតាមរយៈអំណាចនៃដង្វាយធួន ការផ្លាស់ប្រែចិត្តជឿចំពោះសេចក្ដីពិត ហើយគោរពតាមគោលការណ៍ទាំងឡាយនៃសេចក្ដីសុចរិត។

ការបង្រៀនដល់សមាជិក និងក្រុមគ្រួសាររបស់យើង អំពីអ្វីៗដែលទាក់ទងទៅនឹងសេចក្ដីសុចរិត គឺមានសារៈសំខាន់នៅក្នុងដំណើរការនៃការសម្រេចបាននូវការប្រកាន់ខ្ជាប់ចំពោះការផ្លាស់ប្រែចិត្តជឿ ពីព្រោះវាអាចដឹកនាំពួកគេឱ្យទទួលបានចំណេះដឹងត្រឹមត្រូវអំពីព្រះបញ្ញត្តិរបស់ព្រះ គោលការណ៍ និង គោលលទ្ធិទាំងឡាយនៃដំណឹងល្អ និងសេចក្តីត្រូវការ និងពិធីបរិសុទ្ធទាំងឡាយ ដែលយើងត្រូវតែគោរព ដើម្បីសម្រេចបាននូវសេចក្តីសង្គ្រោះនៅក្នុងនគររបស់ព្រះអម្ចាស់។

មានគំរូជាច្រើននៅក្នុងព្រះគម្ពីរ ដែលញ្ជាក់អំពីសារៈសំខាន់នៃការបង្រៀន «អ្វីៗដែលទាក់ទងទៅនឹងសេចក្ដីសុចរិត» ដើម្បីជួយទទួលបាននូវការប្រកាន់ខ្ជាប់ចំពោះការផ្លាស់ប្រែចិត្តជឿ។ នៅក្នុងដំណើររឿងដែលត្រូវបានសរសេរអំពីអាំម៉ូន និងបងប្អូនប្រុសរបស់គាត់ កំពុងផ្សាយដំណឹងល្អនៅក្នុងចំណោមពួកសាសន៍លេមិនយើងអានថា៖

«ហើយអាំម៉ូនបានផ្សាយសាសនាដល់ប្រជាជនរបស់ស្ដេចឡាម៉ូណៃ ហើយហេតុការណ៍បានកើតឡើងថា លោកបាន បង្រៀនពួកគេនូវគ្រប់ការណ៍ទាំងអស់ អំពីការណ៍ទាំងឡាយ ដែលទាក់ទងទៅនឹងសេចក្ដីសុចរិត។ ហើយលោកបាន ទូន្មានពួកគេជារៀងរាល់ថ្ងៃ ដោយអស់ពីការព្យាយាម ហើយពួកគេបានស្ដាប់តាមពាក្យលោក ហើយគេក៏មានចិត្តឧស្សាហ៍ចំពោះការកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ» (អាលម៉ា 21:23)។

យើងអាចមើលឃើញនូវលទ្ធផលនៃការង្រៀនដោយការព្យាយាមនូវអ្វីៗដែលទាក់ទងទៅនឹងសេចក្តីសុចរិត នៅពេលយើងបន្តអានដំណើររឿងនៅក្នុងជំពូកទី 23 និង 27 ដែលនិយាយថា «ក៏មានមនុស្សជាច្រើនបានជឿ ឬក៏មនុស្សជាច្រើនដែលត្រូវបាននាំមកឱ្យស្គាល់សេចក្តីពិត តាមរយៈការផ្សាយរបស់អាំម៉ូន និងបងប្អូនលោក ស្របតាមវិញ្ញាណនៃវិវរណៈ និងវិញ្ញាណនៃការព្យាករណ៍ និព្រះចេស្ដានៃព្រះ ដែលសម្ដែងអព្ភូតហេតុនៅក្នុងពួកគេ... បានប្រែចិត្តជឿដល់ព្រះអម្ចាស់ [នោះ] ពួកគេពុំបោះបង់ចោលសាសនាឡើយ» (អាលម៉ា  23:6)។

នៅពេលអាលម៉ាធំ បានស្ថាបនាសាសនាចក្រ នោះគាត់បានតែងតាំងបុរសសក្តិសម ធ្វើជាពួកសង្ឃ និងគ្រូបង្រៀន របស់ពួកគេដើម្បី «ថែទាំប្រជាជន ហើយបានផ្ដល់ដល់គេ នូវអ្វីៗដែលទាក់ទងទៅនឹងសេចក្តីសុចរិត» (ម៉ូសាយ 23:18)។

ឪពុកម្ដាយដើរតួនាទីដ៏សំខាន់មួយ នៅក្នុងការជួយដល់កូនៗរបស់ពួកគាត់ឱ្យយល់អំពី អ្វីៗដែលទាក់ទងទៅនឹងសេចក្តីសុចរិត។ នៅក្នុងព្រះគម្ពីរមរមន យើងបានរកឃើញថា អាលម៉ា មានការសោកសៅ ដោយសារតែអំពើទុច្ចរិត សង្គ្រាម និងការឈ្លោះទាស់ទែងគ្នាដែលបានមាន ហើយមានទុក្ខព្រួយដោយ

សារភាពរឹងរូសនៅក្នុងដួងចិត្តរបស់ ប្រជាជនលោក «បានចាត់ឱ្យកូនប្រុសៗរបស់លោកមកប្រជុំគ្នា ដើម្បីលោកអាចប្រទានកិច្ចការកាន់កាប់មួយរៀងៗខ្លួន ដាច់ដោយឡែកពីគ្នា អំពីការណ៍ទាំងឡាយដែលទាក់ទងទៅនឹងសេចក្ដីសុចរិត»។ (អាលម៉ា 35:16 បន្ថែមអក្សរទ្រេត)។

វាគួរឱ្យចាប់អារម្មណ៍ដើម្បីដឹងថា គាត់បានបង្រៀន និងផ្ដល់ឱ្យកូនៗរបស់គាត់នូវកិច្ចការកាន់កាប់រៀងៗខ្លួនដាច់ដោយឡែកពីគ្នា កែតម្រូវការបង្រៀនរបស់គាត់ទៅតាមកូនប្រុសម្នាក់ៗ ស្របទៅតាមសេចក្ដីត្រូវការរបស់ពួកគេ។ គាត់បានថ្លែងទីបន្ទាល់ ហើយបានបង្រៀនពួកគេអំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយ រៀបចំពួកគេឱ្យផ្សាយ គោលការណ៍ដូចគ្នាទាំងនោះទៅដល់អ្នកដទៃ។

នៅក្នុងគ្រាមួយ ពេលដែលគ្រួសារស្ថិតនៅក្រោមការវាយប្រហារ មកពីកម្លាំងសេចក្ដីអាក្រក់ និងនៅពេលស្ថានភាពដែលយើងរស់នៅ មានភាពមិនខុសគ្នាប៉ុន្មានពីអ្នកទាំងឡាយដែលអាលម៉ាបានជួបប្រទះនោះគណៈប្រធានទីមួយ និងកូរ៉ុមនៃពួកដប់ពីរនាក់ បានដាក់ចេញនូវ «ក្រុមគ្រួសារ៖ ការប្រកាសដល់ពិភពលោក» ថា «ឪពុកម្ដាយមានកាតព្វកិច្ច ពិសិដ្ឋ ក្នុងការថែរក្សាអប់រំកូនចៅរបស់ខ្លួន ដោយសេចក្ដីស្រឡាញ់ និងដោយសេចក្ដីសុចរិត»។

ការណ៍នេះ រួមមានទាំងការចិញ្ចឹមបីបាច់ ការគាំទ្រ និងការបង្រៀនកូនចៅនៅក្នុងអ្វីៗដែលទាក់ទងទៅនឹងសេចក្ដីសុចរិត ដើម្បីពួកគេអាចនៅតែរឹងមាំ ដោយមានសេចក្ដីពិតក្រវ៉ាត់នៅនឹងចង្កេះរបស់ពួកគេ «ដោយពាក់សេចក្ដីសុចរិតទុកជា ប្រដាប់បាំងដើមទ្រូង ហើយពាក់សេចក្ដីងប្រុងប្រៀបរបស់ដំណឹងល្អនៃសេចក្ដីសុខសាន្តទុកជាស្បែកជើង» (គ. និងស. 27:16)។

ដូចជានៅក្នុងជំនាន់របស់អាលម៉ា ពួកអ្នកដឹកនាំរបស់យើងក៏មើលថែទាំសមាជិក នៃសាសនាចក្រ ហើយចិញ្ចឹមបីបាច់ពួកគេ ជាមួយនឹង អ្វីៗដែលទាក់ទងទៅនឹងសេចក្ដីសុចិរិត ផងដែរ។ អ្វីៗទាំងឡាយនោះនឹងជួយយើងសម្រេចបាននូវការប្រកាន់ខ្ជាប់ចំពោះការផ្លាស់ប្រែចិត្តជឿ។ នៅក្នុងឯកសារ «សេចក្ដីគូសបញ្ជាក់ ការបំពាក់បំប៉នភាពជាអ្នកដឹកនាំ» ដែលបានធ្វើកំណែថ្មី នៅថ្ងៃទី 10 ខែ ធ្នូ ឆ្នាំ 2009 គណៈប្រធានទីមួយ និងកូរ៉ុមនៃពួកដប់ពីរនាក់ សុំឱ្យពួកអ្នកដឹកនាំបព្វជិតភាព និងពួកអ្នកដឹកនាំអង្គការជំនួយ «លើកទឹកចិត្តដល់សមាជិកគ្រួសារម្នាក់ៗ ឪពុកម្ដាយ និងកូនៗ សិក្សាព្រះគម្ពីរ អធិស្ឋានជាទៀងទាត់ ហើយរស់នៅតាមដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ»។

ការសិក្សាព្រះគម្ពីរ ការអធិស្ឋានជាទៀងទាត់ ហើយនឹងការរស់នៅតាមដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ គឺជាកិច្ចការ នៃសេចក្ដីសុចរិត ហើយព្រះអម្ចាស់បានបើកសម្ដែងការសន្យាដ៏អស្ចារ្យនេះថា: «អ្នកណាដែលប្រព្រឹត្តកិច្ចការទាំងឡាយ ដោយសេចក្ដីសុចរិត នោះនឹងបានទទួលរង្វាន់របស់ខ្លួន គឺសេចក្ដីសុខសាន្ត នៅនាលោកិយនេះ និងជីវិតដ៏នៅ អស់កល្បជានិច្ច នៅបរលោកនាយ» (គ. និង ស. 59:23)។

ដើម្បីបង្រៀនឱ្យកាន់តែមានប្រសិទ្ធភាពអំពី អ្វីៗដែលទាក់ទងទៅនឹងសេចក្ដីសុចរិត នោះវាសំខាន់ដើម្បីយល់ថា បន្ថែមពីលើព័ត៌មានដែលបានចែករំលែក នោះយើងត្រូវតែមានជំនួយវិរវណៈ។ តាមរបៀបនេះ មនុស្សដែលត្រូវបាន បង្រៀន អាចទទួលដឹងអំពីបំណងប្រាថ្នា ចង់ដឹងនូវគោលការណ៍ទាំងនេះដោយខ្លួនឯង។

ព្រះអម្ចាស់បានបើកសម្ដែងចំពោះ ហៃរុម ស្ម៊ីធ តាមរយៈប្អូនប្រុសរបស់គាត់ គឺព្យាការីយ៉ូសែប ស្ម៊ីធ ថា៖ «យើងនឹងរំលែកដល់អ្នកនូវព្រះវិញ្ញាណរបស់យើង ដែលនឹងបំភ្លឺគំនិតរបស់អ្នក ដែលនឹងបំពេញព្រលឹងរបស់អ្នកដោយសេចក្ដីអំណរ។

«ហើយខណៈនោះ អ្នកនឹងដឹង...គ្រប់ទាំងអស់ដែលអ្នកមានបំណងចង់បានពីយើង ដែលទាក់ទងទៅនឹងការណ៍ទាំងឡាយនៃសេចក្ដីសុចរិត គឺដោយនូវសេចក្ដីជំនឿ ដោយជឿដល់យើងថា អ្នកនឹងបានទទួលនោះ» (គ. និង ស. 11:13--14)។

នៅទីបញ្ចប់ ព្រះគម្ពីរបានព្រមានយើងអំពីគ្រោះថ្នាក់ នៃការស្លាប់ចំពោះអ្វីៗដែលទាក់ទងទៅនឹងសេចក្ដីសុចរិត ហើយនឹងអំពីលទ្ធផលដ៏ធ្ងន់ធ្ងរនេះ មានចំពោះអ្នកទាំងឡាយ ដែលត្រូវបានបំភ្លឺដោយព្រះវិញ្ញាណនៃព្រះហើយ តែបន្ទាប់មកបានធ្លាក់ក្នុងអំពើបាប និងអំពើរំលង។

ការបង្រៀនអំពីអ្វីៗទាំងឡាយដែលទាក់ទងទៅនឹងសេចក្ដីសុចរិត គឺជាធាតុដ៏មានសារៈសំខាន់មួយ នៅក្នុងការជួយដល់ មនុស្សឱ្យមករកចំណេះដឹងនៃសេចក្ដីពិត ត្រូវបានផ្លាស់ប្រែចិត្តជឿ និងស្ថិតនៅរឹងមាំនៅក្នុងសេចក្ដីជំនឿទៅលើ ព្រះគ្រីស្ទរហូតដល់ទីបំផុត។

ឪពុកម្ដាយមានកាតព្វកិច្ចពិសិដ្ឋ ដើម្បីបង្រៀនដល់កូនចៅរបស់ពួកគាត់ អំពីអ្វីៗដែលទាក់ទងទៅនឹងសេចក្ដីសុចរិត។ ពួកអ្នកដឹកនាំ និងគ្រូបង្រៀន អាចមើលថែទាំ និងចិញ្ចឹមបីបាច់ ដល់សមាជិក ដែលស្ថិតនៅក្នុងការមើលថែរបស់ពួកគាត់ បង្រៀនដល់ពួកគេនូវអ្វីៗទាំងអស់ ដែលទាក់ទងទៅនឹងសេចក្ដីសុចរិត ដោយឧស្សាហ៍ព្យាយាម។

ការណ៍នេះអាចត្រូវបានសម្រេចកាន់តែមានប្រសិទ្ធភាព បើសិនជាវិរវណៈត្រូវបានជួយ នៅអំឡុងពេលកំពុងបង្រៀន ដូច្នេះបានបង្កើតនៅក្នុងខ្លួនមនុស្សនូវបំណងប្រាថ្នា ដើម្បីត្រូវបានបំភ្លឺដោយព្រះវិញ្ញាណ។ បន្ទាប់មកនៅពេលពួកគេ អនុវត្តសេចក្ដីជំនឿ នោះព្រះវិញ្ញាណ អាចធ្វើឱ្យពួកគេដឹងអំពី អ្វីៗដែលទាក់ទងទៅនឹងសេចក្ដីសុចរិត។

ខ្ញុំថ្លែងទីបន្ទាល់អំពីកិច្ចការទាំងនេះ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។